Maine Center for Disease Control and Prevention
An Office of the Department of Health and Human Services

**គន្លឹះសម្រាប់ការប្រើប្រាស់សែកទិញផ្លែឈើ និងបន្លែ (ទំព័រទី 6)--សូមមើលរូបភាពសែកខាងក្រោម៖**

**1. សែកទិញផ្លែឈើ និងបន្លែអាចប្រើប្រាស់នៅបណ្តាហាងដែលអនុម័តដោយ WIC ផ្សារកសិករ ឬស្តង់កសិករ។**

**② មើលកាលបរិច្ឆេទនៅលើសែក WIC ។** កាលបរិច្ឆេទទីមួយ គឺជាថ្ងៃដំបូងដែលអ្នកអាចប្រើប្រាស់សែកនេះបាន។ កាលបរិច្ឆេទទីពីរ គឺជាថ្ងៃចុងក្រោយដែលអ្នកអាចប្រើប្រាស់សែកនេះបាន។ អ្នកអាចប្រើសែក WIC ចំនួនណាមួយក៏បានក្នុងពេលណាមួយដែលមាននៅក្នុងកាលបរិច្ឆេទទាំងនេះបាន។

**③ ពិនិត្យមើលចំនួនទឹកប្រាក់ដុល្លារដែលបានកត់នៅលើសែករបស់អ្នកដែល WIC នឹងរ៉ាប់រង។**

**4. សូមដាក់ផ្លែឈើ និងបន្លែទាំងអស់ជាមួយគ្នា នៅតុគិតលុយ។**

**5 ផ្តល់សឺមី WIC របស់អ្នក និងសែកដែលអ្នកកំពុងប្រើ ឲ្យអ្នកគិតលុយ មុននឹងគេស្កេនមុខទំនិញម្ហូបអាហារ WIC។**

**⑥ សរសេរពីតម្លៃមុខទំនិញម្ហូបអាហារ WIC នៅលើសែកនោះ ប្រសិនបើវាមិនត្រូវបានបោះពុម្ពដោយស្វ័យប្រវត្តិដោយម៉ាស៊ីនគិតលុយរបស់ហាង។** ចំនួនទឹកប្រាក់ដែលបានសរសេរមិនអាចលើសពីតម្លៃនៃប័ណ្ណបានឡើយ។ ប្រសិនបើចំនួនទឹកប្រាក់សរុបច្រើនជាងតម្លៃនៃសែកទិញផ្លែឈើ និងបន្លែនោះ អ្នកត្រូវតែបង់ប្រាក់បង្គ្រប់។ ឧទាហរណ៍៖

- តម្លៃនៃសែកទិញផ្លែឈើ និងបន្លែគឺ $11.00។
- តម្លៃសរុបនៃទំនិញរបស់អ្នកគឺ $12.00 ។
- អ្នកត្រូវតែបង់បន្ថែម $1.00

**ប្រសិនបើការទិញផ្លែឈើ និងបន្លែរបស់អ្នកតិចជាងតម្លៃនៃសែកនោះ អ្នកនឹងមិនទទួលបានលុយអាប់វិញទេ។**

**⑦ ចុះហត្ថលេខាលើផ្នែកខាងមុខនៃសែកនៅជ្រុងខាងស្តាំខាងក្រោម ហើយបន្ទាប់មកប្រគល់សែកនេះឲ្យអ្នកគិតលុយវិញ។** អ្នកគិតលុយនឹងធ្វើឱ្យប្រាកដថា ហត្ថលេខារបស់អ្នកត្រូវគ្នានឹងហត្ថលេខារបស់តំណាងដែលមានការអនុញ្ញាត អ្នកចូលរួម ឬតំណាងពេញសិទ្ធិលើសឺមី WIC ។

**8. ត្រូវប្រាកដថាបានទទួលសឺមី និងវិក្កយបត្ររបស់អ្នក មុនពេលចាកចេញពីតុគិតលុយ ទីផ្សារកសិករ ឬស្តង់កសិករ។**

